ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

---

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ប្រ.ក/លេខ០១.១៨៧/០៧ គ.ជ.ប.អគ្គ.៣ស

ភ្នំពេញ ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៧

# គ.ជ.ប រំលឹកដល់ គខ/កប និង គឃ/សប ពីការចាប់ឆ្នោត កំណត់លំដាប់លេខរៀង

នៅថ្ងៃទី ៩ ខែ មករា ឆ្នាំ ២០០៧ គ.ជ.ប បានចេញសេចក្តីរំលឹកមួយដល់គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត (គខ/កប) និងគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ/សប) អំពីចំណុចមួយចំនួនពាក់ព័ន្ធនឹងការចាប់ឆ្នោតដើម្បីកំណត់លំដាប់លេខរៀងបញ្ជីបេក្ខជនដាក់លើសន្លឹកឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នីតិកាលទី ២ ឆ្នាំ ២០០៧ ។

សេចក្តីរំលឹករបស់ គ.ជ.ប ដែលបានចេញផ្សាយថ្ងៃនេះរំលឹកថា គឃ/សប ត្រូវធ្វើការចាប់ឆ្នោតនៅក្រោយពេលបិទផ្សាយបញ្ជីបេក្ខជនផ្លូវការ គឺនៅពេលដែល គ.ជ.ប មិនបានទទួលបណ្តឹងជំទាស់អំពីបេក្ខជន ឬបញ្ជីបេក្ខជនដំបូង ឬនៅពេលដែលបណ្តឹងជំទាស់អំពីបេក្ខជន ឬបញ្ជីបេក្ខជនដំបូង ត្រូវបានដោះស្រាយចប់ជាស្ថាពរដោយ គ.ជ.ប ។ ក្នុងរយៈពេលបី (៣) ថ្ងៃបន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីដំបូងនៅ គឃ/សប ហើយ គឃ/សប ណាមួយមិនបានទទួលដំណឹងពី គ.ជ.ប អំពីការទទួលបណ្តឹងជំទាស់អំពីបេក្ខជន ឬបញ្ជីបេក្ខជនដំបូងដាក់នៅ គ.ជ.ប ទេ គឃ/សប ត្រូវបិទផ្សាយបញ្ជីបេក្ខជនផ្លូវការ ។ ស្របពេលនេះ គឃ/សប ត្រូវជូនដំណឹងទៅគណបក្សនយោបាយអំពីកាលបរិច្ឆេទនៃការបិទផ្សាយបញ្ជីបេក្ខជនផ្លូវការនេះផង ដើម្បីឱ្យគណបក្សនយោបាយដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងាររបស់ខ្លួននៅ គឃ/សប ក្នុងរយៈពេលយ៉ាងយូរប្រាំពីរ (០៧) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការបិទផ្សាយបញ្ជីបេក្ខជនផ្លូវការ ។

គឃ/សប ត្រូវអនុវត្តនីតិវិធីចាប់ឆ្នោតបន្ទាប់ពី ថ្ងៃបិទផ្សាយបញ្ជីបេក្ខជនផ្លូវការ ដោយអនុវត្តតាម ដូចមានចែងក្រោមប្រការ ៧.២០ នៃបទបញ្ជា និង នីតិវិធី គ.ជ.ប និងត្រូវធ្វើសេចក្តីរាយការណ៍ជាបន្ទាន់អំពី លទ្ធផលនៃការចាប់ឆ្នោតនេះមក គ.ជ.ប តាមរយៈ គខ/កប ។

ចំពោះ គឃ/សប ណាមួយដែលទទួលសេចក្តីជូនដំណឹងពី គ.ជ.ប ថា មានបណ្តឹងជំទាស់អំពីបេក្ខជន ឬបញ្ជីបេក្ខជនដំបូង គឃ/សប ត្រូវរង់ចាំការដោះស្រាយចប់ជាស្ថាពរដោយ គ.ជ.ប ។